ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ០០១ ប្រក.ធទឧ

# ប្រកាស
## ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ របស់ក្រសួងធនធានទឹក និងឧតុនិយម

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធានអាជ្ញាធរទន្លេសាប និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩១៨ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ រកត/០៩០៩/៩៤៣ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញសេចក្តីសម្រេចលេខ ៦១៣៣/២៣ មស.សសរ ស្តីពីការកំណត់សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៃក្រសួង ស្ថាប័ន
- បានឃើញលិខិតលេខ ០១៥/២៣ មស.អគកស.លស ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងមុខងារសារណៈ
- បានឃើញការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម។

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងធនធានទឹក និងឧតុនិយម រួមមានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ចាន់ យុត្ថា** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **នាក់ ដាង** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-លោកជំទាវ | **វ៉ាន់ ចាន់ថូ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤-ឯកឧត្តម | **ម៉េង ម៉ូគន្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល | អនុប្រធាន |
| ៥-ឯកឧត្តម | **ឈុន ពុទ្ធារិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស | សមាជិក |
| ៦-ឯកឧត្តម | **ហ៊ីង ស៊ុនថាន** | អគ្គាធិការ | សមាជិក |
| ៧-ឯកឧត្តម | **ហៃល តូនី** | អនុប្រធានអាជ្ញាធរទន្លេសាប | សមាជិក |
| ៨-ឯកឧត្តម | **តែ ណាវុធ** | អនុប្រធានអចិន្ត្រៃគណៈកម្មាធិការជាតិទន្លេមេគង្គ | សមាជិក |



# អគារលេខ: ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៦ ៦៧០
#364, Monivong BLVD, Phsar Deumthkov, Chamkarmon, Phnom Penh, Cambodia, Phone: (855)23 216 670

| | | | |
|---|---|---|---|
| ៩.ឯកឧត្តម **សរ គឹមសាន្ត** | | អគ្គលេខាធិការនៃអាជ្ញាធរទន្លេសាប | សមាជិក |
| ១០.ឯកឧត្តម **សូ សុភ័ន្ធ** | | អគ្គលេខាធិការនៃគណៈកម្មាធិការជាតិទន្លេមេគង្គ | សមាជិក |
| ១១.លោក **សុខ ចំណាន** | | អគ្គនាយករងកិច្ចការរដ្ឋបាល | សមាជិក |
| ១២.លោក **ម៉ម ប្រុស** | | ប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | សមាជិកអចិន្ត្រៃយ៍ |
| ១៣.លោក **ឃ្លោក សំអាង** | | ប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤.លោក **មុយ មុនិន្ទ** | | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ១៥.លោក **ថាច់ សុវណ្ណា** | | ប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក | សមាជិក |
| ១៦.លោក **យិន សាវុធ** | | ប្រធាននាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ | សមាជិក |
| ១៧.លោក **អ៊ុំ វីណា** | | ប្រធាននាយកដ្ឋានឧតុនិយម | សមាជិក |
| ១៨.លោក **ថាំង វីយុទ្ធជា** | | ប្រធាននាយកដ្ឋានធារាសាស្ត្រកសិកម្ម | សមាជិក |
| ១៩.លោក **សែម សំណាង** | | ប្រធាននាយកដ្ឋានទឹកស្អាត និងអនាម័យ | សមាជិក |
| ២០.លោក **ហៀង ម៉េង** | | ប្រធាននាយកដ្ឋានវិស្វកម្ម | សមាជិក |
| ២១.លោក **នូ សុខិន** | | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ២២.លោក **អ៊ុច ហ៊ីង** | | ប្រធានមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម | សមាជិក |
| ២៣.លោក **ហ៊ុយ ទ៉ាន់ថា** | | ប្រធាននាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក | សមាជិក |
| ២៤.លោក **អ៊ូ សុផាន់ណា** | | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃគណៈកម្មាធិការជាតិទន្លេមេគង្គ | សមាជិក |
| ២៥.លោក **ឡុក សីលា** | | ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និង សហប្រតិបត្តិការ នៃអាជ្ញាធរទន្លេសាប | សមាជិក |
| ២៦.លោក **សៅ សម្ភារ** | | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | សមាជិក |
| ២៧.លោក **ជុំ សិនិទ្ធ** | | ប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | សមាជិក |
| ២៨.លោក **ជិន សិរីរតនៈ** | | ប្រធានការិយាល័យបុគ្គលិក នៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | សមាជិក |
| ២៩.លោក **នាង សំអាត** | | អនុប្រធានការិយាល័យបណ្ដុះបណ្ដាល នៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | សមាជិក |
| ៣០.លោក **អ៊ុំ លក្ស្មី** | | អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | សមាជិក |
| ៣១.លោកស្រី **សុត បុប្ផា** | | អនុប្រធានការិយាល័យបុគ្គលិក នៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | សមាជិក។ |

**ប្រការ២.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងធនធានទឹក និងឧតុនិយម មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលដំណើរការទូទៅ និងជំរុញការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង
- ចូលរួមអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាក្នុងនោះផ្ដោតទៅលើ៖ (១)ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រី (២)ការលើកកម្ពស់ប្រសិទ្ធភាពការងារ និង(៣)ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម
- អនុវត្តការត្រួតពិនិត្យឡើងវិញ និងវិភាគមុខងាររបស់ក្រសួង

- រៀបចំ និងអភិវឌ្ឍកម្មវិធីពង្រាយមន្ត្រីរាជការ
- រៀបចំ និងអភិវឌ្ឍកម្មវិធីដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី និងក្រសួង
- រៀបចំផែនការសកម្មភាពការងារកែទម្រង់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយបន្សុីទៅនឹងវិធានការគន្លឹះទាំងបី របស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដោយសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ចូលរួមកិច្ចប្រជុំទៀងទាត់ប្រចាំត្រីមាស និងផ្អែកតាមការចាំបាច់ តាមការអញ្ជើញរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពិនិត្យវឌ្ឍនភាពការងារ បញ្ហាប្រឈម ដំណោះស្រាយ និងវិធានការនានា
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួង ស្ដីពីវឌ្ឍនភាពការងារជាប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ
- អនុវត្តតាមភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី និងប្រធានក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងធនធានទឹក និងឧតុនិយម។

**ប្រការ៣.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង មានរបៀបរបបធ្វើការងារដូចខាងក្រោម៖

- ប្រជុំមួយខែម្ដង និងប្រជុំដទៃទៀតតាមការអញ្ជើញរបស់ប្រធានក្រុមការងារ
- កិច្ចប្រជុំត្រូវដឹកនាំដោយប្រធាន ឬអនុប្រធាន តាមការប្រគល់សិទ្ធិរបស់ប្រធាន
- កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្ដាល នៃចំនួនសមាជិកក្រុមការងារទាំងអស់
- រាល់កិច្ចប្រជុំរបស់ក្រុមការងារត្រូវមានកំណត់ហេតុ ឬរបាយការណ៍ដែលចុះហត្ថលេខាដោយប្រធានអង្គប្រជុំ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គនាយក អគ្គាធិការ អគ្គលេខាធិការ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធចំណុះក្រសួង និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមិគសិរ ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមករា ឆ្នាំ ២០២៤

**រដ្ឋមន្ត្រី**

**ចៅ ជេដ្ឋា**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ថ្នាក់ដឹកនាំក្រសួង
- ដូចក្នុងប្រការ ៥
- ឯកសារ-កាលប្បវត្តិ